# ប្រភពនៃទស្សនវិជ្ជាអប់រំៈ ប្រតិបត្តិនិយម និងអត្ថិភាពនិយម

*ដោយៈ* **បណ្ឌិត សូ សុធីរ**
*មន្ត្រីស្រាវជ្រាវនាយកដ្ឋានវិទ្យាសាស្ត្រអប់រំ*
*វិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម*
*រាជបណ្ឌិត្យសភាកម្ពុជា*

## សេចក្តីផ្តើម

*ប្រតិបត្តិនិយមគឺជាប្រពៃណីទស្សនវិជ្ជាដែលចាត់ទុកភាសា និងការគិតជាឧបករណ៍សម្រាប់ការទស្សន៍ទាយការដោះស្រាយបញ្ហា និងសកម្មភាព ជាជាងការពិពណ៌នា ការបង្ហាញ ឬការឆ្លុះបញ្ចាំងតថភាព។ ប្រតិបត្តិនិយមវិទូ អះអាងថា ប្រធានបទទស្សនវិជ្ជាភាគច្រើន ដូចជាធម្មជាតិនៃចំណេះដឹង ភាសា គោលគំនិត អត្ថន័យ ជំនឿ និងវិទ្យាសាស្ត្រ សុទ្ធតែត្រូវបានមើលយ៉ាងល្អបំផុតទាក់ទងនឹងការប្រើប្រាស់ជាក់ស្តែង និងភាពជោគជ័យរបស់ពួកគេ។ ប្រតិបត្តិនិយម បានចាប់ផ្តើមនៅសហរដ្ឋអាម៉េរិកក្នុងទសវត្សរ៍ឆ្នាំ១៨៧០។*

*អត្ថិភាពនិយមគឺជាទម្រង់នៃការសិក្សាស្រាវជ្រាវទស្សនវិជ្ជាដែលស្វែងយល់ពីបញ្ហានៃអត្ថិភាពរបស់មនុស្ស។ ទស្សនវិទូអត្ថិភាពនិយម ស្រាវជ្រាវបញ្ហាទាក់ទងនឹងអត្ថន័យ គោលបំណង និងតម្លៃនៃអត្ថិភាពរបស់មនុស្ស។ គំនិតទូទៅនៅក្នុងគំនិតអត្ថិភាពនិយមរួមមានវិបត្តិអត្ថិភាព ការភ័យខ្លាច និងការថប់បារម្ភ ចំពោះមុខពិភពលោក ដែលមិនសមហេតុផល និងឥទ្ធៈសេរី ក៏ដូចជាភាពត្រឹមត្រូវ ភាពក្លាហាន និងគុណធម៌។*

*អត្ថិភាពនិយមត្រូវបានផ្សារភ្ជាប់ជាមួយនឹងទស្សនវិទូអឺរ៉ុប នៅសតវត្សរ៍ទី១៩និងសតវត្សរ៍ទី២០ ដែលបានចែករំលែកការសង្កត់ធ្ងន់លើប្រធានបទរបស់មនុស្ស ទោះបីជាជារឿយៗ មានភាពខុសគ្នាយ៉ាងជ្រាលជ្រៅ នៅក្នុងគំនិតក៏ដោយ។*

## ១-ប្រតិបត្តិនិយម

### ក-ស្ថាបនិកប្រតិបត្តិនិយម

*ប្រតិបត្តិនិយម អះអាងបញ្ជាក់នូវតម្រូវការ ដើម្បីធ្វើតេស្តគំនិត តាមការធ្វើសកម្មភាពទៅលើគំនិតទាំងនោះ។ ក្នុងចំណោមស្ថាបនិកទាំងឡាយគឺ* Charles S. Peirce (1839-1914), William James (1842-1910), George Herbert Mead (1863-1931), *និង* John Dewey (1859-1952)។

-Peirce *បានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់* ***វិធីវិទ្យាសាស្ត្រ*** *ដើម្បីធ្វើឱ្យមានតុល្យភាពគំនិតតាមបែបសង្កេតពិសោធ។*

-James បានអនុវត្តទស្សនវិជ្ជាប្រតិបត្តិនិយម ទៅនឹងចិត្តវិទ្យា សាសនា និងការអប់រំ។

-Mead បានអះអាងបញ្ជាក់ការអភិវឌ្ឍកុមារថា ជាការសិក្សា និងការពិសោធអ្វីៗ ដែលមានជីវិតរបស់មនុស្ស។

-Dewey បានអនុវត្តដល់ការអប់រំ[1]។

នៅទីនេះ យើងផ្តោតអារម្មណ៍ ទៅលើទស្សនវិជ្ជាប្រតិបត្តិនិយម ឬពិសោធនិយម ដែលធ្វើជាការផ្លាស់ប្តូរ ជាពិសេសលំនាំសាបេក្ខភាព និងការស្ថាបនាឡើងវិញនូវបទពិសោធ។

**ខ-សព៌ាង្គកាយ និងបរិស្ថាន**

ដោយទទួលបានទ្រឹស្តីវិវត្តរបស់ Charles Darwin នោះ Dewey បានអនុវត្តវាក្យសព្ទសព៌ាង្គកាយ និងបរិស្ថាន ចំពោះការអប់រំ។ Dewey បានមើលឃើញមនុស្សជាតិថាជាសរីរាង្គមានជីវិតផ្នែកសង្គមសាស្ត្រ និងជីវសាស្ត្រ ដែលមានចំណង់ និងពលវេគ ដែលទ្រទ្រង់ជីវិត និងជំរុញការលូតលាស់ និងការអភិវឌ្ឍ។ គ្រប់សរីរាង្គមានជីវិតរស់នៅក្នុងជម្រកមួយ និងបរិស្ថាន។ ការអប់រំ គឺជាលំនាំមួយនៃការបង្កើតបរិស្ថានសិក្សា ដែលនឹងជំរុញដល់បទពិសោធទាំងឡាយ សម្រាប់ការលូតលាស់មនុស្សដ៏ប្រសើរបំផុត។

**គ-ការដោះស្រាយបញ្ហា**

ទោះបីជាមនោនិយម និងតថនិយម បានសង្កត់ធ្ងន់ទៅលើអង្គនៃពុទ្ធិដ៏សំខាន់ក៏ដោយ ក៏កម្មវត្ថុសិក្សាតាមមុខវិជ្ជានោះ Dewey បានសង្កត់ធ្ងន់ ទៅលើលំនាំនៃការដោះស្រាយបញ្ហា។ សម្រាប់ Dewey ការសិក្សា កើតមានឡើង នៅពេលដែលមនុស្ស បានចូលរួមក្នុងការដោះស្រាយបញ្ហា។ នៅក្នុងទ្រឹស្តីនៃចំណេះដឹងនោះ សិស្សក្នុងនាមជាបុគ្គលម្នាក់ ឬជាសមាជិកនៃក្រុមមួយ ប្រើប្រាស់វិធីវិទ្យាសាស្ត្រ ដើម្បីដោះស្រាយទាំងបញ្ហាបុគ្គលទាំងសង្គម។ សម្រាប់ Dewey វិធីដោះស្រាយបញ្ហា អាចត្រូវបានអភិវឌ្ឍទៅជាទម្លាប់ ដែលប្រែក្លាយទៅជាស្ថានភាពផ្សេងៗដ៏ទូលំទូលាយ[2]។

**៤-១-បញ្ញត្តិជាគន្លឹះ**

**ក-បទពិសោធ**

**បរមត្ថវិជ្ជា និងពុទ្ធិវិទ្យា** មិនដូចមនោនិយម និងតថនិយម ដែលទាំងពីរពឹងផ្អែកទៅលើមូលដ្ឋានគ្រឹះខាងបរមត្ថវិជ្ជានៃតថភាពសកល និងថេរនោះ ប្រតិបត្តិនិយម ឬបទពិសោធនិយម កម្ចាត់បរមត្ថវិជ្ជា ថាជាការសន្មត ដែលគេមិនអាចផ្ទៀងផ្ទាត់បាន។ លើសពីបរមត្ថវិជ្ជា ប្រតិបត្តិនិយម មានការពាក់ព័ន្ធជាខ្លាំងនឹងពុទ្ធិវិទ្យា។

[1] John Dewey, *The Child and the Curriculum* (Chicago: University of Chicago Press, 1902); John Dewey, *Democracy and Education* (New York: Macmillan, 1916; Jonh Dewey, *The School and Society* (Chicago: University of Chicago Press, 1923); and Jonh Dewey, *Experience and Education: The 60 th Anniversary Edition* (West Lafayette, Ind.: Kappa Delta Pi, 1998).

[2] Lawrence J. Dennis and George W. Stickel, Mead and Dewey: Thematic Connections on Educational Topics, *Educational Theory* (Summer-Fall 1981), pp. 320-321.

នៅក្នុងទស្សនវិជ្ជានៃបទពិសោធនិយមរបស់ Dewey ស្ថានភាពពុទ្ធិវិទ្យា ពាក់ព័ន្ធនឹងមនុស្ស ឬអ្វី ដែលមានជីវិត និងបរិស្ថាន។ បទពិសោធដែលបានកំណត់ន័យថាជាអន្តរកម្មរវាងមនុស្ស និងបរិស្ថាននោះ ជាបញ្ញត្តិគន្លឹះ។ មនុស្សធ្វើអន្តរកម្មជាមួយបរិស្ថាន ដើម្បីរស់នៅ លូតលាស់ និងអភិវឌ្ឍ។ អន្តរកម្មនេះអាចផ្លាស់ប្តូរ ទាំងមនុស្ស ទាំងបរិស្ថាន។ ដូច្នេះ ការចេះដឹងគឺជាកិច្ចការលំនាំរវាងសិស្ស និងមជ្ឈដ្ឋាន[3]។

## ខ-តេស្តនៃបទពិសោធ

ដោយជំទាស់នឹងទស្សនវិស័យមនោនិយម និងតថនិយមមុនៗ Dewey បានអនុវត្តតេស្តមួយពីបទពិសោធ។ ផែនការ និងគោលបំណងមនុស្សអាចត្រូវបានធ្វើឱ្យមានសុពលភាពតែម្យ៉ាង តាមសកម្មភាពនិងការវិនិច្ឆ័យ វាតាមផលរបស់វា។ ថ្វីបើអន្តរកម្មនីមួយៗ មានទិដ្ឋភាពអាចធ្វើទូទៅកម្ម ដែលអាចអនុវត្តចំពោះបញ្ហានាពេលបន្ទាប់ ដែលឧបកថានីមួយៗ នឹងខុសគ្នាបន្តិបន្តួច។ មនុស្សដ៏មានប្រសិទ្ធភាព ប្រើប្រាស់វិធីវិទ្យាសាស្ត្រ ដើម្បីដោះស្រាយបញ្ហា និងបន្ថែមផ្នែកគួរឱ្យកត់សម្គាល់នៃឧបកថាដោះស្រាយបញ្ហា ពិសេសចំពោះបទពិសោធដែលចេះតែបន្តរបស់គេ។

Dewey ក៏បានអនុវត្តការវិនិច្ឆ័យ តាមផលចំពោះការអប់រំ។ តើកម្មវិធីអប់រំពិសេសការរៀបចំកម្មវិធីសិក្សាឬល្បិចតាមវិធីសាស្ត្រសម្រេចបានគោលដៅ និងវត្ថុបំណង ដែលបានទទ្ទឹងរង់ចាំឬទេ? Dewey ជឿជាក់ថាតេស្តដែលមានសុពលភាព ត្រូវសាកល្បងសំណើ និងវិនិច្ឆ័យលទ្ធផល[4]។

## គ-មិនមានតថភាពអចិន្ត្រៃយ៍, ការកសាងឡើងវិញនៃមនុស្ស និងបរិស្ថាន

តថភាពដែលផ្លាស់ប្តូរជាបន្តបន្ទាប់ផ្តល់ឱ្យកម្មវិធីសិក្សា ដោយពឹងផ្អែកទៅលើតថភាពជាអចិន្ត្រៃយ៍ ឬសច្ចភាពសាកល ដែលមិនអាចការពារបាន។ មនុស្សលោក ត្រូវតែធ្វើអន្តរកម្មជាមួយបរិស្ថាន ដែលត្រូវបាននាំផ្លូវតែម្យ៉ាង ដោយការអះអាង ដែលមិនទាន់ប្រាកដអាស្រ័យទៅលើការស្រាវជ្រាវ និងការផ្ទៀងផ្ទាត់បន្ថែម។ ហេតុដូច្នោះ យោងទៅតាមពួកប្រតិបត្តិនិយម យើងត្រូវការវិធីមួយ សម្រាប់ធ្វើការពិភាក្សាជាមួយការផ្លាស់ប្តូរ តាមរបៀបមួយឈ្លាសវៃ។ ទ្រឹស្តីរបស់ Dewey សង្កត់ធ្ងន់ទៅលើការដោះស្រាយបញ្ហា ជាវិធីដ៏មានប្រសិទ្ធភាពបំផុត សម្រាប់ការដឹកនាំ ការផ្លាស់ប្តូរ ចំពោះលទ្ធផល ដែលចង់បាន។ ទោះបីជាតថភាព ពាក់ព័ន្ធនឹងការផ្លាស់ប្តូរ ឬការកសាងឡើងវិញទាំងមនុស្សទាំងបរិស្ថាននោះ មនុស្ស

---

3 For an analysis of Deweyan's Pragmatic Perspective, see Christine L. McCarthy and Evelyn Sears, Deweyan Pragmatism and the Quest for True Self, *Educational Theory* (Spring 2000), pp. 213-227

4 Stephen M. Fishman and Lucille McCarthy, Jonh Dewey and the Challenge of Classroom Practice (New York: Teachers Colloge Press, 1998)

ជាតិ អាចទទួលប្រយោជន៍ពីលំនាំនេះ។ គ្រប់បទពិសោធមនុស្ស ដែលគេបានបង្កើតឡើង ដើម្បីដោះស្រាយបញ្ហាមួយ បានបង្កើនបទពិសោធមនុស្សថែមទៀត។

**ឃ-សាបេក្ខភាពនៃតម្លៃ វិទ្យាសាស្ត្រសីលធម៌និងតក្កវិជ្ជា**

វិទ្យាសាស្ត្រសីលធម៌តាមប្រតិបត្តិនិយម គឺមានលក្ខណៈទៅតាមស្ថានភាពកម្រិតខ្ពស់។ ចក្រវាឡ ដែលកំពុងផ្លាស់ប្តូរជាប្រចាំ មានន័យថា តម្លៃ ត្រូវតែផ្លាស់ប្តូរផងដែរ និងមានការទាក់ទងទៅនឹងពេលវេលា ទីកន្លែង និងកាលៈទេសៈ។ អ្វីដែលរួមចំណែកដល់ការលូតលាស់សង្គម និងបុគ្គល យើងចាត់ទុកថាមានតម្លៃ។ អ្វីដែលរឹតបន្តឹង ឬកំណត់ដែនបទពិសោធមនុស្ស គឺមិនមានតម្លៃទេ។ ជាងនេះទៀត យើង ក៏អាចធ្វើុះបញ្ជាំងតម្លៃរបស់យើងតាមការធ្វើតេស្ត និងការកសាងឡើងវិញ តាមរបៀបតែមួយ ដែលយើងផ្ទៀងផ្ទាត់តាមការទាមទារបែបវិទ្យាសាស្ត្រ[5]។

**ខ-តក្កវិជ្ជាបែបអនុមានរួម**

ដោយអនុវត្តតាមវិធីវិទ្យាសាស្ត្រ តក្កវិជ្ជាតាមបែបពិសោធនិយមគឺមានលក្ខណៈ អនុមានរួម ជាជាងអនុមានញែក អំពីគោលការណ៍ដំបូង ដូចជាមនោនិយមនិងតថនិយម។ ការបញ្ជាក់អះអាង ដែលមិនទាន់ជាក់លាក់ពឹងផ្អែកទៅលើភស្តុតាង តាមបែបសង្កេតពិសោធ ហើយត្រូវតែធ្វើតេស្ត។

**៤-២-សំណួរជាមូលដ្ឋាន**

**ក-ចំណេះដឹង ដែលមិនទាន់មានភាពជាក់លាក់**

ចម្លើយរបស់ពួកប្រតិបត្តិនិយម ចំពោះសំណួរអំពីចំណេះដឹង ការអប់រំ ការសិក្សា និងការបង្រៀន ខុសគ្នាយ៉ាងសំខាន់ពីពួកមនោនិយម និងតថនិយម។ ពីព្រោះការទាមទារចំណេះដឹង មិនទាន់មានលក្ខណៈជាក់លាក់ និងអាស្រ័យទៅលើការរំលឹកសាឡើងវិញនោះ ពួកប្រតិបត្តិនិយម មានការជាប់ទាក់ទងយ៉ាងជិតស្និទ្ធជាមួយលំនាំនៃការបង្កើត និងការប្រើប្រាស់ចំណេះដឹងជាងជាមួយសច្ចភាពដែលជាអង្គនៃចំណេះដឹងជាអចិន្ត្រៃយ៍។

**ខ-លំនាំតាមបែបពិសោធ**

ពួកប្រតិបត្តិនិយម ចាត់ទុកការអប់រំជាលំនាំបទពិសោធ គឺវិធីនៃការដោះស្រាយបញ្ហា ដែលស្វែងរកការពិតពីមនុស្ស នៅពេលដែលពួកគេធ្វើអន្តរកម្ម ជាមួយនឹងពិភពរបស់គេ។ Dewey បានអះអាងថាមនុស្សជាតិឆ្លងកាត់បទពិសោធនូវការលូតលាស់ផ្នែកសង្គម និងបុគ្គលដ៏ធំធេងបំផុត នៅពេលដែលគេធ្វើអន្តរកម្មជាមួយបរិស្ថានតាមលក្ខណៈឈ្លាសវៃនិងរិះគិត

---

[5] William R. Caspary, Judgements of Value in Jonh Dewey's Theory of Ethics, *Educational Theory* (Spring 1990), pp. 155-169. See also Robert B. Westbrook, *Jonh Dewey and American Democracy* (Ithaca, N.Y.: Cornell University Press, 1991), pp. 151-156.

ពិចារណា។ របៀបល្អបំផុតនៃការដោះស្រាយបញ្ហា គឺត្រូវប្រើប្រាស់វិធីវិទ្យាសាស្ត្រ។

**គ-គោលវិធីអន្តរមុខវិជ្ជា**

ពួកប្រតិបត្តិនិយម គាំទ្រដល់ការអប់រំដែលមានមុខវិជ្ជារួមគ្នា។ ពួកគេនិយាយថា នៅពេលដែលអ្នកប្រឈមមុខនឹងបញ្ហា អ្នកទាញយកព័ត៌មាន ដែលអ្នកត្រូវការ ដើម្បីដោះស្រាយវាពីប្រភពជាច្រើន មិនមែនពីផ្នែក ឬមុខវិជ្ជាតែមួយទេ។

ឧទាហរណ៍ ដើម្បីកំណត់បញ្ហានៃភាពកខ្វក់ក្នុងបរិស្ថាន និងការផ្តល់យោបល់ក្នុងការដោះស្រាយវា យើងត្រូវតែពិចារណាប្រភពទាំងឡាយ ដែលមានលក្ខណៈជាប្រវត្តិសាស្ត្រ នយោបាយ សង្គមវិជ្ជា វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងអន្តរជាតិ។

តាមន័យបែបប្រតិបត្តិនិយម មនុស្សដែលមានការអប់រំ ដឹងពីរបៀបអនុវត្តព័ត៌មានពីប្រភពទាំងនេះចំពោះបញ្ហា។ ផ្ទុយពីទស្សនៈពួកប្រតិបត្តិនិយមនេះ ពួកមនោនិយម និងតថនិយម មានការសង្ស័យពីការអប់រំអន្តរមុខវិជ្ជាពីព្រោះគេជឿថា សិស្ស ត្រូវតែទទួលបានមូលដ្ឋានចំណេះដឹងជាលើកដំបូង តាមការសិក្សាពីប្រធានវិស័យដែលបានរៀបចំរួមគ្នា។

**ឃ-សាលារៀនជាគំរំណែនប្រជាធិបតេយ្យ និងការផ្ទេរមត៌កវប្បធម៌**

ពួកប្រតិបត្តិនិយម ដូចជា Dewey មើលឃើញសហគមន៍សិស្ស និងគ្រូ នៅតាមមូលដ្ឋានតូចតាច មានការពាក់ព័ន្ធជាខ្លាំងទៅនឹងសង្គមធំជាងនេះ។ សាលារៀន បានហ្វឹកហាត់មុខងារចម្បងបីដួយសម្រួលបន្សុទ្ធ និងធ្វើឱ្យមានតុល្យភាពដល់មរតកវប្បធម៌។

-ដើម្បីជួយសម្រួល ឬធ្វើឱ្យមានភាពងាយស្រួល សាលារៀន ជ្រើសរើសជាតុនៃមរតក និងកាត់បន្ថយភាពស្មុគស្មាញ ទៅនឹងក្រុម ដែលសមរម្យ ចំពោះចំណូលចិត្ត និងភាពត្រៀម ជាស្រេចរបស់សិស្ស។

-ដើម្បីបន្សុទ្ធ វាជ្រើសរើសជាតុខាងវប្បធម៌ដ៏មានតម្លៃ និងលុបបំបាត់ជាតុទាំងឡាយ ដែលកំណត់ដែនដល់ការលូតលាស់ និងអន្តរកម្មមនុស្ស។

-ដើម្បីធ្វើមានតុល្យភាព សាលារៀនធ្វើអន្តរកម្មបទពិសោធដែលបានជ្រើសរើស និងបន្សុទ្ធ ទៅជាភាពចុះសម្រុងនឹងគ្នា។

**ខ-វប្បធម៌ផ្សេងៗគ្នា តែលំនាំសិក្សាមានលក្ខណៈរួមគ្នា**

នៅក្នុងសង្គម ដែលមានក្រុមវប្បធម៌ផ្សេងៗគ្នានោះ សាលារៀនប្រតិបត្តិនិយម ជួយសិស្សដែលមានវប្បធម៌មួយ យល់ និងវាយតម្លៃសមាជិកនៃវប្បធម៌ផ្សេងៗទៀត។ ទោះបីជាភាពផ្សេងគ្នាខាងវប្បធម៌ ជួយកែលំអសង្គមទាំងមូលក៏ដោយក៏ពួកប្រតិបត្តិនិយមចង់ឱ្យក្រុមវប្បធម៌ទាំងអស់ ប្រើប្រាស់វិធីវិទ្យាសាស្ត្រ។ ពួកគេក៏ជឿជាក់ថា សាលារៀន គួរស្ថាបនាមតិទូទៅផ្នែកសង្គម ដោយសង្កត់ធ្ងន់ ទៅលើលំនាំសិក្សាទូទៅ។ ព្រោះតែមានសហគមន៍សិក្សាបែបប្រជាធិបតេយ្យ និងសមាហរណកម្មដ៏ពិត

*ប្រាកដនោះ សាលារៀន គួរតែបើកចំហ ដល់ជនទាំងអស់គ្នា និងលើកទឹកចិត្តដល់ការរួមចំណែក នៃធនធានដែលអាចធ្វើទៅបាន ដោយទូលំទូលាយ ក្នុងចំណោមមនុស្សនៃវប្បធម៌ទាំងអស់។*

### ៤-៣-ការអនុវត្តសម្រាប់គ្រូប្រចាំថ្នាក់នាពេលបច្ចុប្បន្ន

#### ក-កម្មវត្ថុមុខវិជ្ជា ជាឧបករណ៍

*គ្រូបង្រៀនមនោនិយមនិងតថនិយម មើលឃើញកម្មវត្ថុមុខវិជ្ជាបង្រៀន ថាជាការទទួលខុសត្រូវដំបូង ប៉ុន្តែ គ្រូបង្រៀនប្រតិបត្តិនិយម យកចិត្តទុកដាក់នឹងលំនាំនៃការដោះស្រាយបញ្ហា ប្រកបដោយភាពវាងវៃច្រើនជាង។ ជាជាងធ្វើមិនដឹងមិនឮ ទៅលើកម្មវត្ថុមុខវិជ្ជា ពួកគេបង្កើតវានូវឧបករណ៍មួយក្នុងស កម្មភាពដោះស្រាយបញ្ហា។ ពួកគេមិនគ្រប់គ្រងថ្នាក់រៀនទេ ប៉ុន្តែដឹកនាំការសិក្សា ក្នុងនាមជាអ្នកជួយសម្របសម្រួលសកម្មភាព និងការស្រាវជ្រាវរបស់និស្សិត។ គ្រូបង្រៀនប្រតិបត្តិនិយម ក៏ជួយសិស្សផងដែរ ឱ្យរកឃើញប្រភពផ្សេងទៀតដែលមានប្រយោជន៍ នៅក្នុងការដោះស្រាយបញ្ហាដូចជាអ្នកទាំងឡាយ ដែលអាចទទួលបាន តាមបច្ចេកវិទ្យាក្នុងថ្នាក់រៀន[6]។*

#### ខ-ការអនុវត្តវិធីវិទ្យាសាស្ត្រ

*សិស្សនៅក្នុងថ្នាក់រៀនពួកប្រតិបត្តិនិយម បែងចែកបទពិសោធនៃការអនុវត្តវិធីវិទ្យាសាស្ត្រ ទៅដល់កម្រិតពេញលេញនៃបញ្ហាបែបបុគ្គលសង្គមនិងឈ្លាសវៃ។គ្រូបង្រៀនរំពឹងថា សិស្សដោយប្រើវិធីវិទ្យាសាស្ត្រ នឹងសិក្សាដើម្បីអនុវត្តលំនាំចំពោះបញ្ហាទាំងក្នុងនិងក្រៅសាលារៀន ហើយភ្ជាប់សាលារៀនទៅនឹងសង្គម។ បច្ចេកវិទ្យាទំនាក់ទំនង ដូចជា អ៊ីមេល និងអ៊ីនធឺណិត ក៏បង្កើតទំនាក់ទំនងទូលំទូលាយជាងជាមួយឱកាសច្រើនជាង ដើម្បីបែងចែកការប្រើប្រាស់រួមគ្នានូវគំនិត ការយល់ដឹង និងបទពិសោធទាំងឡាយ។*

#### គ-ថ្នាក់រៀនមួយជាសហគមន៍

*គ្រូបង្រៀនប្រតិបត្តិនិយម ធ្វើការងារដើម្បីផ្លាស់ប្តូរថ្នាក់រៀន ទៅជាសហគមន៍សិក្សាបែបសហការ* (Collaborative learning communities) *តាមការលើកទឹកចិត្ត ឱ្យចេះបែងចែកប្រយោជន៍របស់ពួកគេ និងបញ្ហា។ អ្នកអប់រំប្រតិបត្តិនិយម ក៏លើកទឹកចិត្ត ទាំងភាពផ្សេងគ្នាខាងវប្បធម៌ ទាំងភាពទូទៅផងដែរ។ ទោះបីជាគេទទួលស្គាល់ថា វប្បធម៌នីមួយៗមានតម្លៃអ្វីមួយ ដើម្បីរួមចំណែកដល់វប្បធម៌ផ្សេងទៀតក៏ដោយ ក៏គេបានអះ អាងបញ្ជាក់នូវទំនាក់ទំនងរួមគ្នា រវាងសមា ជិកនៃវប្បធម៌ផ្សេងៗគ្នា ដើម្បីឱ្យសិស្សទាំងអស់គ្នា អាចជួយបង្កើតសហគមន៍ប្រជាធិបតេយ្យធំទូលាយជាងនេះទៀត។ ជំនួសឱ្យការរក្សាតំណែងទាំង*

[6] For an examination of the philosophical implications of technology, see Larry A. Hickman, *Philosophical Tools for Technological Culture* (Bloomington: Indiana University Press, 2001).

នេះ គ្រូបង្រៀន ត្រូវតែប្រថុយ។ ពួកគេត្រូវតែមើលឃើញចំណោះដឹងថា គ្មានដែនកំណត់ និងបើកចំហ ហើយគោលដៅអប់រំរបស់ពួកគេត្រូវតែបង្កើតការអង្កេតជាបន្ត ដែលនាំដល់សកម្មភាព។

**ឃ-ស្តង់ដា និងការវាយតម្លៃ សំណួរដែលជាចលនាស្តង់ដា**

ពួកប្រតិបត្តិនិយម នឹងលើកសំណួរសំខាន់ៗ អំពីចលនាស្តង់ដា ជាពិសេស ការពឹងផ្អែកជាខ្លាំង ទៅការធ្វើតេស្ត តាមស្តង់ដា។ តេស្តបែបនេះ ជាបន្ទុកដល់សិស្សជាមួយគោលដៅ និងការរំពឹងទុកជាមុន ដែលកំណត់ដោយមនុស្ស និងភ្នាក់ងារផ្សេងទៀត ជាជាងអ្នកទាំងឡាយ ដែលលើកឡើងពីបទពិសោធ និងបញ្ហាសិស្សផ្ទាល់ខ្លួន។ ជាងនេះទៀត តេស្តដែលប្រើក្រដាស និងសរសេរដោយខ្មៅដៃវាស់បានតែរបៀបដែលសិស្សទទួលយកបានខ្លឹមសារ ដែលបានកំណត់ទុកប្រសើរជាងបំណិនដោះស្រាយប ញ្ហាតេស្តដោយពិតប្រាកដបានល្អប៉ុណ្ណា។ គ្រូដែលសមត្ថភាពរបស់គាត់ ត្រូវបានវិនិច្ឆ័យតាមថា តើសិស្សធ្វើតេស្តតាមស្តង់ដាបានល្អប៉ុណ្ណានោះ ផ្តោតអារម្មណ៍ការបង្រៀនទៅលើការធ្វើតេស្តជាប់ជាជាងការដោះ ស្រាយបញ្ហា។

**៥-អត្ថិភាពនិយម** ( Existentialism )

អត្ថិភាពនិយម ដែលតំណាងឱ្យទាំងអារម្មណ៍នៃការត្រៀមប្រយុទ្ធ ទៅនឹងភាពអស់សង្ឃឹម (Desperation) និងស្មារតីនៃក្តីសង្ឃឹម (A spirit of hope) នោះ ***សិក្សាអំពីជីវិត តាមជម្រើសផ្ទាល់ខ្លួន ឬជាបុគ្គល។*** ការអប់រំតាមបែបអត្ថិភាពនិយម លើកទឹកចិត្តការឆ្លុះបញ្ចាំង ជាបុគ្គលយ៉ាងជ្រាលជ្រៅ ទៅលើអត្តសញ្ញាណ ការសន្យា និងការជ្រើសរើសរបស់អ្នកណាម្នាក់។

**៥-១-បញ្ញត្តិជាគន្លឹះ**

**ក-ការឆ្លុះបញ្ចាំងជាបុគ្គល និងការបង្កើតខ្លឹមសារដ៏សំខាន់របស់ខ្លួន តាមការជ្រើសរើស**

អ្នកនិពន្ធអត្ថិភាពនិយម Jean-Pual Satre (1905-1980) បានអះអាងថា អត្ថិភាព នាំមុខខ្លឹមសារដ៏សំខាន់។ តាមន័យផ្សេងទៀត មនុស្សលោក បានកើតឡើង នៅក្នុងពិភពលោក ដោយគ្មានបានពិគ្រោះយោបល់។ យើងរស់នៅក្នុងពិភពលោកយ៉ាងសាមញ្ញ ដែលយើងមិនបានបង្កើតឡើង។ ទោះជាយ៉ាងនេះក្តី មនុស្សយើង មានឆន្ទៈ ហើយត្រូវបង្កើតការជ្រើសរើស និងបង្កើតគោលបំណងនៃអត្ថិភាពផ្ទាល់ខ្លួនរបស់យើង។ ក្នុងជីវិតរបស់យើង យើងត្រូវឆ្លងកាត់ស្ថានភាព ដែលបង្កើតការជ្រើសរើស។ ការជ្រើសរើសមួយចំនួន គឺមានលក្ខណៈមិនស៊ីជម្រៅ ប៉ុន្តែ អ្នកទាំងឡាយដែលយកចិត្តទុកដាក់នឹងគោលបំណង និងអត្ថន័យនៃជីវិត នាំទៅរកការកំណត់ន័យផ្ទាល់ខ្លួន។ យើងបង្កើតនិយមន័យផ្ទាល់ខ្លួន និងបង្កើតខ្លឹមសារផ្ទាល់ខ្លួនរបស់យើង។ ពួកអត្ថិភាពនិយម និយាយថា សេរីភាពរបស់

មនុស្ស មានភាពពេញលេញ ដូចជាការទទួលខុសត្រូវ សម្រាប់ការជ្រើសរើស[7]។

**ខ-ភាពភ័យខ្លាចបែបអត្ថិភាពនិយម**

គំនិតនៃមនុស្សលោក ជាអ្នកបង្កើតខ្លឹមសារដោយផ្ទាល់ខ្លួន ខុសប្លែកគ្នាជាខ្លាំងពីពួកមនោនិយម និងតថនិយម ដែលមើលឃើញមនុស្សម្នាក់ថាជាប្រភេទសកល។ ជាងនេះទៀត ដោយហេតុថា ពួកមនោនិយម ឬតថនិយម មើលឃើញបុគ្គលថា ជាអ្នកស្រុកម្នាក់នៃពិភពដ៏មានន័យ និងដែលអាចពន្យល់បាននោះ ពួកអត្ថិភាពនិយម ជឿជាក់ថា ចក្រវាឡ មានភាពមិនខុសគ្នានឹងផែនការចំណង់ និងក្តីប្រាថ្នារបស់មនុស្ស។ អត្ថិភាពនិយម ផ្តោតអារម្មណ៍ទៅ លើបញ្ញត្តិនៃភាពភ័យខ្លាច និងអន្ទះសារជាខ្លាំង។ យើងម្នាក់ៗដឹងថា វាសនារបស់យើង គឺសេចក្តីស្លាប់ និងវត្តមានរបស់យើងក្នុងពិភពលោក គឺជារឿងបណ្តោះអាសន្ន។ ក្នុងន័យនៃការភ័យខ្លាច តាមទស្សនវិជ្ជានេះ មនុស្សម្នាក់ៗ ត្រូវតែធ្វើការជ្រើសរើសអំពីសេរីភាព និងទាសករ សេចក្តីស្រឡាញ់ និងស្អប់សន្តិភាព និងសង្គ្រាម។ នៅពេលដែលយើងធ្វើការសម្រេចចិត្ត នេះ យើងអនុវត្តសំណួរ តើវាធ្វើឱ្យមានភាពខុសគ្នាបែបណា ដែលថា ខ្ញុំនៅទីនេះ និងខ្ញុំ បានជ្រើសរើសធ្វើជាមនុស្សបែបណា?

**គ-ការជ្រើសរើសការតាំងចិត្តដោយខ្លួនឯង**

យោងទៅតាមពួកអត្ថិភាពនិយម យើងត្រូវតែដោះស្រាយដោយជោគជ័យផងដែរជាមួយការគំរាមកំហែងជាប្រចាំ ដូចជា មនុស្សស្ថាប័ន និងភ្នាក់ងារ ដែលជាសេរីភាពជ្រើសរើសរបស់យើង។ ការឆ្លើយតបរបស់បុគ្គលម្នាក់ចំពោះជីវិត ធ្ងុះបញ្ហាំងច ម្ល៉ើយទៅនឹងសំណួរ តើខ្ញុំជ្រើសរើស ដើម្បីធ្វើជាមនុស្ស ដែលបានតាំងចិត្តដោយខ្លួនឯង ឬខ្ញុំជ្រើសរើស ដើម្បីកំណត់ន័យដោយអ្នកផ្សេង? ប៉ុន្តែ ពួកអត្ថិភាពនិយម ពិតជាបានមើលឃើញក្តីសង្ឃឹមនៅខាងក្រោយការប្រយុទ្ធ ដើម្បីក្តីសង្ឃឹម។ មនុស្សម្នាក់ៗ មានសក្តានុពល សម្រាប់ការស្រឡាញ់ ការបង្កើតច្នៃប្រឌិដ្ឋ និងការរស់នៅ។ មនុស្សម្នាក់ៗ អាចជ្រើសរើស ដើម្បីធ្វើជាមនុស្ស ដែលមានភាពត្រឹមត្រូវ មិនបង្ហាញឱ្យឃើញផ្ទាល់។ មនុស្សដែលមានភាពត្រឹមត្រូវ ដែលមានសេរីភាព និងយល់ដឹងនូវសេរីភាព ដឹងថា គ្រប់ការជ្រើសរើសស្ថិតក្នុងការពិត ដែលជាសកម្មភាពនៃការច្នៃប្រឌិដ្ឋតម្លៃដោយបុគ្គល[8]។

[7] Gutek, *Philosophical and Ideological Voices in Education*, pp. 85-86.

[8] Maxine Greene, Landscapes of Learning (New York: Teachers College Press, 1978); and Van Cleve Morris, Existentialim in Education (New York: Harper and Row, 1986).

## ៥.២-សំណួរជាមូលដ្ឋាន

### ក-ការបង្កើតតម្លៃបុគ្គល

ពីព្រោះតែពួកអត្ថិភាពនិយម បានជៀសវាងដោយចេតនានូវប្រព័ន្ធកម្មនៃទស្សនវិជ្ជារបស់ពួកគេនោះ វាជារឿងលំបាក ដើម្បីធ្វើចំណាត់ថ្នាក់ស្ថានភាពបែបតក្កវិទ្យា វិទ្យាសាស្ត្រ សីលធម៌ ពុទ្ធិវិទ្យា បរមត្ថវិជ្ជា។ ដូចដែលបានអះអាងបញ្ជាក់រួចមកហើយ ពួកអត្ថិភាពនិយម ជឿជាក់ថា យើងអាចបង្កើតការកំណត់ន័យផ្ទាល់ ឬខ្លឹមសារផ្ទាល់ខ្លួន តាមការជ្រើសរើស ជាបុគ្គល ដែលយើងបង្កើត។ តាមពុទ្ធិវិទ្យា បុគ្គលជ្រើសរើសចំ ណេះដឹង ដែលគេចង់ទទួលបាន។ ពួកអត្ថិភាពនិយម ចាត់ទុកវិទ្យាសាស្ត្រសីលធម៌ ជារឿងសំខាន់បំផុត ពីព្រោះមនុស្សលោកប ង្កើតតម្លៃផ្ទាល់ខ្លួនគេតាមការជ្រើសរើស។

### ខ-ការដាស់ញាណនៃលក្ខខណ្ឌមនុស្ស

ពួកអត្ថិភាពនិយមដឹងថា យើងរស់នៅក្នុងពិភពនៃតថភាពរូបវន្ត ហើយយើងបានអភិវឌ្ឍចំណេះដឹងបែបវិទ្យាសាស្ត្រ និងមានប្រយោជន៍អំពីតថភាពទាំងនេះ។ ទោះជាយ៉ាងនេះក៏ដោយ ចំណុចដ៏សំខាន់បំផុតនៃជីវិតរបស់យើង មានលក្ខណៈផ្ទាល់ខ្លួន ហើយមិនមែនជាវិទ្យាសាស្ត្រទេ។ ដូច្នោះហើយពួកអត្ថិភាពនិយមជឿជាក់ថា ចំណេះ ដឹងអំពីលក្ខខណ្ឌមនុស្ស និងការជ្រើសរើសជាបុគ្គលដែលយើងបង្កើតនោះ គឺមានសារៈសំខាន់បំផុត ហើយគោលដៅសំខាន់បំផុតរបស់ការអប់រំ ត្រូវដាស់ញាណរបស់មនុស្ស ដើម្បីសេរីភាព ក្នុងការជ្រើសរើស និងដើម្បីបង្កើតន័យពីការយល់ដឹងផ្នែកអត្តៈ ដែលរួមចំណែកដល់ភាពត្រឹមត្រូវរបស់យើង។

### គ-ឱកាសតែមួយសម្រាប់មនុស្សទាំងអស់

ពួកអត្ថិភាពនិយមនិយាយថា នៅសាលារៀនបុគ្គលទាំងឡាយ គួរតែបន្តពិភា ក្សាអំពីជីវិត និងការជ្រើសរើសផ្ទាល់ខ្លួន។ ព្រោះយើងទាំងអស់គ្នាស្ថិតក្នុងស្ថានភាពលំបាកដូចគ្នា និងលទ្ធភាពដូចគ្នានោះ យើងទាំងអស់គ្នា គួរតែមានឱកាសសិក្សាអប់រំ។ នៅសាលារៀនទាំងគ្រូទាំងសិស្សគួរមានឱកាស ដើម្បីសួរសំណួរ ផ្តល់ចម្លើយ និងចូលរួមដល់ការសន្ទនា។

### ឃ-ការសួរសំណួរនិងការសន្ទនា និងកម្មវិធីសិក្សាតាមបែបអត្ថិភាពនិយម

គ្រូបង្រៀនតាមបែបអត្ថិភាពនិយម គួរលើកទឹកចិត្តសិស្សឱ្យគិតតាមបែបទស្សនវិជ្ជា សួរសំណួរ និងចូលរួមក្នុងការសន្ទនាអំពីអត្ថន័យនៃជីវិត សេចក្តីស្រឡាញ់ និងមរណភាព។ ចម្លើយចំពោះសំណួរទាំងនេះគួរតែមានលក្ខណៈជាបុគ្គល និងសត្យានុម័ត មិនមែនវាស់វែង តាមគេស្តស្តង់ដានោះទេ។ កម្មវិធីសិក្សាតាមបែបពួកអត្ថិភាពនិយម និងមានអ្វីដែលអាចនាំដល់ការសន្ទនាតាមបែបទស្សនវិជ្ជា។ ជាពិសេស មុខវិជ្ជាមានតម្លៃ ពិពណ៌នា

យ៉ាងជាក់លាក់ បុរស និងនារីជាបុគ្គល ក្នុងការជ្រើសរើស រាប់បញ្ចូលទាំងមុខវិជ្ជាផ្នែកកំណាព្យ សោកំណានិង ចិត្តរំភើប[9]។ អក្សរសិល្ប៍ និងជីវប្រវត្តិ មានសារៈសំខាន់សម្រាប់លាតត្រដាងលក្ខខណ្ឌបង្កើត ការជ្រើសរើស។ សិស្សគួរតែទស្សនា និងពិភាក្សាល្ខោន និងភាពយន្ត ដែលរៀបរាប់យ៉ាងជាក់លាក់នូវលក្ខខណ្ឌមនុស្ស និងការបង្កើតការសម្រេចចិត្តរបស់មនុស្ស។

**ខ-ការបង្ហាញពីអត្តដែលចាំបាច់**

ក្នុងការបន្ថែមទៅឱ្យមុខវិជ្ជាជីវវិទ្យា នាដសាស្ត្រ និងអក្សរសិល្ប៍នោះ សិស្សត្រូវតែបង្កើតបែបបទនៃការបង្ហាញអត្ត[10]។ ពួកគេគួរតែមានសេរីភាព ដើម្បីធ្វើការពិសោធជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយផ្នែកសិល្បៈ និងបង្កើតព្រឹត្តិការណ៍ រឿងល្ខោននូវចិត្តរំភើបសញ្ចេតនា និងការយល់ដឹង។ បច្ចេកវិទ្យាតាមបែបអប់រំ ដែលជួយដល់ការជ្រើសរើសបុគ្គល និងសេរីភាព អាចមានប្រយោជន៍ដល់ការអប់រំ។

ឧទាហរណ៍ សិស្សអាចទទួលបានប្រយោជន៍ពីការបង្ហាញខ្លួនគេ តាមការបង្កើតផលិតកម្មពហុការផ្សព្វផ្សាយ។ ការអនុវត្តបច្ចេកវិទ្យាដែលបង្កើតសភាពដូចគ្នាក្នុងការគិត និងក្នុងការទទួលបានព័ត៌មាន និងត្រូវបានគេយល់ដោយភាពសង្ស័យ។

**៥-៣-ការអនុវត្តសម្រាប់គ្រូបង្រៀនប្រចាំថ្នាក់នាពេលសព្វថ្ងៃ**

**ក-គ្រូបង្រៀន ត្រូវលើកទឹកចិត្តការយល់ដឹង**

ការបង្រៀនពីទស្សនវិស័យបែបអត្ថិភាពនិយម មិនមែនងាយស្រួលទេ ពីព្រោះគ្រូ មិនអាចបញ្ជាក់គោលដៅនិងវត្ថុបំណងជាមុន ដែលទាំងនេះ ត្រូវបានកំណត់ ដោយសិស្ស ម្នាក់ៗក្នុងនាមជាមនុស្សម្នាក់ៗ។ ជាងនេះទៀតការព្យាយាមធ្វើឱ្យសិស្សទទួលបានគោលដៅទាំងឡាយនោះ គ្រូបង្រៀនតាមអត្ថិភាពនិយម ស្វែងរកបង្កើតការយល់ដឹងពីសិស្សម្នាក់ៗ នៃការទទួលខុសត្រូវកម្រិតកំពូលសម្រាប់ការអប់រំ និងការកំណត់ន័យសេចក្តីពីអត្តៈ។ ក្នុងការបង្កើតការយល់ដឹងនេះ គ្រូបង្រៀនលើកទឹកចិត្តសិស្សឱ្យពិនិត្យមើលការចាប់ផ្តើមអនុវត្ត កម្លាំង និងស្ថានភាពដែលកំណត់សេរីភាពនៃការជ្រើសរើស ដោយមានបរិស្ថានសិក្សាទូលំទូលាយបែបនេះ ការបង្រៀន គឺជារឿងស្វ័យតម្រង់ទិស។

---

[9] Maxine Greene, The Dialectic of Freedom (New York: Teachers College Press, 1988)

[10] For an approach that uses narrative and dialogue to examine philosophical issues in education, see Carol Witherell and Nel Noddings, eds., *Stories Lives Tell: Narrative and Dialogue in Education* (New York: Teachers College Press, 1991).

### ខ-ស្តង់ដា និងការវាយតម្លៃស្តង់ដាផ្នែកខាងក្រៅ ធ្វើឱ្យការអប់រំបុគ្គលិកលក្ខណៈស្រុតចុះ

ពួកអត្ថិភាពនិយម បានប្រឆាំងនឹងចលនាស្តង់ដានេះ ជាពិសេសការសង្កត់ធ្ងន់ទៅលើការធ្វើតេស្តតាមស្តង់ដា ដើម្បីវាស់វែងភាពជោគជ័យខាងការសិក្សា។ ចលនា ស្តង់ដាទាំងមូល គឺជានិន្នាការមួយ ដែលឃ្លាតឆ្ងាយពីឯកត្តភាព និងជម្រើស និងសេរីភាពរបស់បុគ្គល។ ការបង្រៀននៅតាមគ្រប់ថ្នាក់រៀន ត្រូវធ្វើតាមស្តង់ដាតែមួយ លុបបំបាត់ចោលនូវអត្តចរិតប្លែកៗ នៃការកំណត់ការអប់រំនីមួយៗ។

## ៥-៤-សាលារៀនបែបអត្ថិភាពនិយម

### ក-Summerhill: គំរូមួយនៃសេរីភាព

ទោះបីជាសាលារៀន Summmerhill របស់ A. S. Neill នៅចក្រភពអង់គ្លេស ផ្តល់ឱ្យធ្វើចំណាត់ថ្នាក់ដ៏មានរបៀបរៀបរយ តាមទស្សនវិជ្ជាអប់រំក៏ដោយ ក៏វាបានផ្តល់នូវឧទាហរណ៍ពីប្រធានបទបែបអត្ថិភាពនិយមតាមបេសកកម្ម កម្មវិធីសិក្សា និងគោលវិធីចំ ពោះការបង្រៀន និងរៀន។ Neill បានបង្កើតសាលារៀនរបស់គាត់ ជាបទពិសោធអប់រំតាមសេរីភាព ដើម្បីជ្រើសរើសអ្វី និងពេលណាដែលគេចង់សិក្សា។ នៅពេលដែលគេរួចផុតពីការរឹតបន្តឹង និងការហាមឃាត់ តាមបទបញ្ញត្តិពីខាងក្រៅនោះ Neill រកឃើញថា សិស្សពិតជាចង់សិក្សា ហើយចង់បន្តរបៀបសិក្សាផ្ទាល់ខ្លួនជាខ្លាំង[11]។

### ខ-មេរៀនបែបអត្ថិភាពនិយម

អក្សរសាស្ត្រ វិនាដសាស្ត្រ និងភាពយន្តមានឥទ្ធិពលជាពិសេសខាងការបង្រៀន បែបអត្ថិភាពនិយម។ គំរូមួយនៃការបង្រៀនបែបជាថ្នាក់រៀនប្រវត្តិវិទ្យា នៅវិទ្យាល័យ ដែលកំពុងសិក្សាហាយនភាព (Holocaust) គឺរបបប្រល័យពូជសាសន៍នៃជនជាតិជ្វីហ្វដែលមានចំនួន៦លាននាក់ នៅទ្វីបអឺរ៉ុបក្នុងអំឡុង ពេលសង្គ្រាមលោកលើកទី២។ សិស្សក្នុងថ្នាក់រៀន ទស្សនាភាពយន្តរបស់ Steven Spilberg រឿង **Schindler's List** ដែលក្នុងនោះ ចាងហ្វាងភាពយន្តដ៏ធំឈ្មោះ Oscar Schindler ដែលជាអ្នកទទួលបានប្រយោជន៍ជាលើកដំបូង ពីពលកម្មដោយបង្ខំនៃមនុស្ស ដែលរស់នៅកន្លែងប្រមូលផ្តុំឃុំឃាំងជនជាតិជ្វីហ្វនោះ បានបង្កើតការសម្រេចចិត្តប្រកបដោយញាណ ដើម្បីសង្គ្រោះកម្មករពីសេចក្តីស្លាប់ នៅក្នុងបន្ទប់ឃុំឃាំងឧស្ម័ន ឬសាំង ពួកណាស៊ីស (The Nazi gas chambers)។ បន្ទាប់មក សិស្សក្នុងថ្នាក់រៀន សង្កេតស្ថានភាពសីលធម៌នៃមនុស្សម្នាក់គឺ Schindler និងការជ្រើសរើស ដែលគាត់បានបង្កើតក្នុងពិភពដ៏សែនព្រៃផ្សៃ និងឥតសមហេតុផល។

---

[11] Neill described his approach to education in A. S. Summerhill: *A Radical Approach to Child Rearing* (New York: Hart Publishing, 1960); also see his autobiography, *Neill! Neill! Orange Peel!*(New York: Hart publishing, 1972). The Wed site for Neill's Summerhill School is **http:www.summerhillschool.co.uk./pages/index.html**

## សន្និដ្ឋាន

ទ្រឹស្តីប្រតិបត្តិនិយម ដែលទទួលបានពីការទ្រពីលោក Childs, Dewey, James, និង Pierce ជាទ្រឹស្តីសំខាន់មួយ នៅក្នុងទស្សនវិជ្ជា ត្រូវបានគេយកទៅប្រតិបត្តិក្នុងវិស័យអប់រំ ដើម្បីរៀបចំការបង្រៀន ដើម្បីដោះស្រាយបញ្ហា ដោយយោងទៅតាមវិធីវិទ្យាសាស្ត្រ ។

ទ្រឹស្តីអត្ថិភាពនិយម ដែលទទួលបានពីការគាំទ្រពីលោក Sartre, Marcel, Morris, និង Soderquis ជាទ្រឹស្តីសំខាន់មួយ នៅក្នុងទស្សនវិជ្ជា ដែលត្រូវបានគេយកទៅប្រតិបត្តិក្នុងវិស័យអប់រំ ដើម្បីរៀបចំការសន្ទនានៅក្នុងថ្នាក់រៀន ក្នុងការភ្ញោចដល់ការយល់ដឹង ដែលគេអាចបង្កើតស្វ័យបញ្ញត្តិ តាមជម្រើសដ៏សំខាន់ចាំបាច់។

## ឯកសារយោង


1- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 2008.
2- Allan C. Ornstein et al., *Foundation of Education*, Wadsworth, Canada. 20011.
3- Jonh Dewey, *Experience and Education: The 60 th Anniversary Edition*, West Lafayette, Ind.: Kappa Delta Pi, 1998.
4- Lawrence J. Dennis et al.: *Thematic Connections on Educational Topics*, *Educational Theory*, Summer-Fall 1998.
5- Christine L. McCarthy and Evelyn Sears, *Deweyan Pragmatism and the Quest for True Self*, *Educational Theory*, Spring 2000.
6- Stephen M. Fishman and Lucille McCarthy, Jonh Dewey, *the Challenge of Classroom Practice*, New York: Teachers Colloge Press, 1998.
7- William R. Caspary, *Judgements of Value in Jonh Dewey's Theory of Ethics*, *Educational Theory*, Spring 1990.
8- Robert B. Westbrook, *Jonh Dewey and American Democracy*, Ithaca, N.Y.: Cornell University Press, 1991.
9- Larry A. Hickman, *Philosophical Tools for Technological Culture*, Bloomington: Indiana University Press, 2001.
10- Maxine Greene, *Landscapes of Learning*, New York: Teachers College Press, 1978.
11- Van Cleve Morris, *Existentialim in Education*, New York: Harper and Row, 1986.
12- Maxine Greene, *The Dialectic of Freedom*. New York: Teachers College Press, 1988.
13- Carol Witherell and Nel Noddings, *Stories Lives Tell: Narrative and Dialogue in Education*, New York: Teachers College Press, 1991.
14- A. S. Summerhill: *A Radical Approach to Child Rearing*. New York: Hart Publishing, 1960.